# 6 ចំណុចដែលត្រូវដឹងអំពីអត្រានៃការបញ្ចប់ការសិក្សា

## តើអ្វីទៅជាអត្រានៃការបញ្ចប់ការសិក្សា?
មធ្យមភាគនៃភាគរយសិស្សដែលបញ្ចប់ការសិក្សាក្នុងរយៈពេលបួនឆ្នាំបន្ទាប់ពីចូលថ្នាក់ទីប្រាំបួន និងភាគរយនៃសិស្សដែលបញ្ចប់ការសិក្សាក្នុងរយៈពេលប្រាំ ឬប្រាំមួយឆ្នាំបន្ទាប់ពីចូលថ្នាក់ទីប្រាំបួន។

## ហេតុអ្វីបានជាអត្រានៃការបញ្ចប់ការសិក្សាមានសារៈសំខាន់?
ការទទួលបាននូវសញ្ញាប័ត្រ គឺជាសមិទ្ធផលដ៏ធំធេងមួយ ហើយជាព្រឹត្តិការណ៍សំខាន់មួយក្នុងជីវិតរបស់សិស្ស។ ការវាស់ស្ទង់លទ្ធផលនេះ កំណត់គោលដៅបញ្ចប់ការសិក្សាប្រចាំឆ្នាំ សម្រាប់ចំនួនសិស្សដែលបញ្ចប់ការសិក្សា "ទាន់ពេល" នៅរដ្ឋ Maine ក៏ដូចជាសិស្សដែលបញ្ចប់ការសិក្សានៅអាត្រាផ្សេងទៀត ប៉ុន្តែអាចទទួលយកបាន។

## តើអ្វីទៅជាគោលដៅបញ្ចប់ការសិក្សាប្រចាំឆ្នាំ?
គោលដៅរយៈពេលវែងសម្រាប់អត្រានៃការបញ្ចប់ការសិក្សារយៈពេលបួនឆ្នាំ គឺត្រូវមានសិស្ស 90% បញ្ចប់ការសិក្សាក្នុងរយៈពេលបួនឆ្នាំបន្ទាប់ពីចូលរៀនថ្នាក់ទីប្រាំបួន។ គោលដៅរយៈពេលវែងសម្រាប់អត្រានៃការបញ្ចប់ការសិក្សាដែលពន្យារពេល គឺត្រូវមានសិស្ស 92% បញ្ចប់ការសិក្សាក្នុងរយៈពេលប្រាំ ឬប្រាំមួយឆ្នាំបន្ទាប់ពីចូលថ្នាក់ទីប្រាំបួន។

## ហេតុអ្វីបានជារដ្ឋ Maine តាមដានអត្រានៃការបញ្ចប់ការសិក្សា?
ច្បាប់សហព័ន្ធស្តីពីការជោគជ័យរបស់សិស្សរាល់រូប (ESSA) ទាមទារឱ្យរដ្ឋនីមួយៗមានប្រព័ន្ធគណនេយ្យភាពដែលរួមមានអត្រានៃការបញ្ចប់ការសិក្សា ជាអាំងឌីកាទ័រនៃវឌ្ឍនភាព និងភាពជោគជ័យរបស់សាលា។

## តើទិន្នន័យបានមកពីណា?
ទិន្នន័យនៃការបញ្ចប់ការសិក្សាត្រូវបានប្រមូលសម្រាប់សិស្សសាលាសាធារណៈទាំងអស់ជារៀងរាល់ឆ្នាំដោយក្រសួងអប់រំរដ្ឋ Maine។

## តើវានឹងបង្ហាញយ៉ាងណាលើប័ណ្ណរបាយការណ៍សាលា?
សាលារៀន ជារួម នឹងទទួលបានការវាស់ស្ទង់លទ្ធផលមួយដែលទាក់ទងទៅនឹងក្រុមសិស្សនានាដែលសម្រេចគោលដៅនៃការបញ្ចប់ការសិក្សាប្រចាំឆ្នាំ។